**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៥៦ ប្រក.កសក

លិខិតចូល
ថ្ងៃទី០៣ ខែ១១ ឆ្នាំ២០១០

# ប្រកាស

## ស្តីពី

## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តក្រចេះ

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ

ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

### ប្រការ ១.-

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តក្រចេះ សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈ សហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតនៅក្នុងផ្នែករដ្ឋបាលព្រៃឈើក្រចេះ ផ្នែករដ្ឋបាលព្រៃឈើឆ្លូង ផ្នែករដ្ឋបាលព្រៃឈើព្រែកប្រសព្វ នៃខណ្ឌរដ្ឋបាលព្រៃឈើក្រចេះ។

### ប្រការ ២.-

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង :

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវៈចម្រុះ និង អភិវឌ្ឍព្រៃសហគមន៍ឱ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណី សម្រាប់ការរស់នៅ ទំនៀមទម្លាប់ និង ជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមសក្តានុពល និង លទ្ធភាពធនធានព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

### ប្រការ ៣.-

តំបន់ព្រៃសហគមន៍ក្នុងខេត្តក្រចេះនៃប្រកាសនេះមាន ១១ សហគមន៍ព្រៃឈើ ចែកចេញជា ១១ កន្លែង ដែលមានផ្ទៃដីសរុបចំនួន ២១.៥៩៨ (ម្ភៃមួយពាន់ប្រាំរយហាសិបប្រាំបី) ហិកតា ដូចមានក្នុងផែនទី ទីតាំងព្រៃសហគមន៍ និង ផែនទីសហគមន៍នីមួយៗភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និង ជាប្រព័ន្ធខ្សែព្រំប្រទល់ កំណត់ដោយចំណុចគោលនិងនិយាមកា ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

### ប្រការ ៤.-

ដំណើរការរៀបចំ និង ការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើ ក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះត្រូវអនុវត្តតាមនីតិវិធី ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និង ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

### ប្រការ ៥.-

ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦.-

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋានទីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានមន្ទីរកសិកម្មខេត្តក្រចេះ និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០

ចាន់ សារុន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តក្រចេះ
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ១ : ប្រកាសលេខ..... ប្រ.កសក ចុះថ្ងៃទី ២៣ ខែ ..... ឆ្នាំ ២០១០



ឧបសម្ព័ន្ធ ២ : ភ្ជាប់ប្រកាសលេខ ៥៥៦...... ចុះថ្ងៃទី ២១...ខែ សីហា..... ឆ្នាំ ២០២២....

# ទីតាំងព្រៃសហគមន៍ក្នុងខេត្តក្រចេះ

| ល.រ | ឈ្មោះសហគមន៍ | ផ្ទៃដី (ហិកតា) | និយាមកា | | | | | | | ចំនួនភូមិ | ឃុំ | ស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | កំណត់បណ្តាញប្រព័ន្ធពិភពភាគ ឥណ្ឌា ១៩៦០ | | | | | | | | | | |
| ១ | ស្រែរនាម | ២០២១ | ជើង | A | 658704 | 1363670 | B | 665205 | 1362891 | ១ | ឃ្សឹម | ស្នួល | ឆ្លូង |
| | | | កើត | B | 665205 | 1362891 | C | 659325 | 1358613 | | | | |
| | | | ត្បូង | C | 659325 | 1358613 | D | 656311 | 1362835 | | | | |
| | | | លិច | D | 656311 | 1362835 | A | 658704 | 1363670 | | | | |
| ២ | ស្ទឹងធំ | ៦៣៨ | ជើង | A | 584802 | 1366285 | B | 587354 | 1366292 | ១ | ចំបក់ | ព្រែកប្រសព្វ | ព្រែកប្រសព្វ |
| | | | កើត | B | 587354 | 1366292 | C | 588498 | 1364234 | | | | |
| | | | ត្បូង | C | 588498 | 1364234 | D | 584820 | 1364246 | | | | |
| | | | លិច | D | 584820 | 1364246 | A | 584802 | 1366285 | | | | |
| ៣ | ស្ទឹងទ្រ | ២៣៩២ | ជើង | A | 594499 | 1367320 | B | 599125 | 1370489 | ១ | តាម៉ៅ | ព្រែកប្រសព្វ | ព្រែកប្រសព្វ |
| | | | | B | 599125 | 1370489 | C | 599126 | 1363046 | | | | |
| | | | កើត | C | 599126 | 1363046 | D | 597040 | 1363041 | | | | |
| | | | ត្បូង | D | 597040 | 1363041 | E | 594499 | 1364484 | | | | |
| | | | លិច | E | 594499 | 1364484 | A | 594499 | 1367320 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤ | ភ្នំលោក | ១៣៣៤ | ជើង | A | 602139 | 1363253 | B | 605578 | 1363261 | ១ | គំពង់គរ | ព្រែកប្រសព្វ | ព្រែកប្រសព្វ |
| | | | កើត | B | 605578 | 1363261 | C | 607014 | 1360073 | | | | |
| | | | ត្បូង | C | 607014 | 1360073 | D | 602100 | 1360058 | | | | |
| | | | លិច | D | 602100 | 1360058 | A | 602139 | 1363253 | | | | |
| ៥ | ស្រែជិះ | ២៧៣០ | ជើង | A | 662333 | 1433917 | B | 664386 | 1435555 | ១ | ស្រែជិះ | សំបូរ | ក្រចេះ |
| | | | | B | 664386 | 1435555 | C | 669869 | 1432423 | | | | |
| | | | កើត | C | 669869 | 1432423 | D | 669878 | 1430420 | | | | |
| | | | ត្បូង | D | 669878 | 1430420 | E | 662333 | 1430872 | | | | |
| | | | លិច | E | 662333 | 1430872 | A | 662333 | 1433917 | | | | |
| ៦ | រលួស | ១១៦៣ | ជើង | A | 654184 | 1435083 | B | 657285 | 1434138 | ១ | រលួសមានជ័យ | សំបូរ | ក្រចេះ |
| | | | កើត | B | 657285 | 1434138 | C | 656911 | 1432600 | | | | |
| | | | ត្បូង | C | 656911 | 1432600 | D | 652475 | 1432812 | | | | |
| | | | លិច | D | 652475 | 1432812 | A | 654184 | 1435083 | | | | |
| ៧ | ច្រវា | ១២១៦ | ជើង | A | 620979 | 1388666 | B | 626225 | 1388670 | ១ | គោលាប់ | ក្រចេះ | ក្រចេះ |
| | | | កើត | B | 626225 | 1388670 | C | 626225 | 1386416 | | | | |
| | | | ត្បូង | C | 626225 | 1386416 | D | 620979 | 1386134 | | | | |
| | | | លិច | D | 620979 | 1386134 | A | 620979 | 1388666 | | | | |
| | | | ជើង | A | 643019 | 1433550 | B | 646303 | 1432202 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៨ | រ៉ៅក្អែ | ១៩៤០ | ជើង | B | 646303 | 1432202 | C | 648482 | 1433124 | ១ | វាលួសមានជ័យ | សំបូរ | ក្រចេះ |
| | | | កើត | C | 648482 | 1433124 | D | 649243 | 1430116 | | | | |
| | | | ត្បូង | D | 649243 | 1430116 | E | 643265 | 1430121 | | | | |
| | | | លិច | E | 643265 | 1430121 | A | 643019 | 1433550 | | | | |
| ៩ | តំបន់សក្តានុពលព្រៃឈើបឹងចារ | ៥៥៨៤ | ជើង | A | 612210 | 1450908 | B | 614149 | 1449491 | ១ | បឹងចារ | សំបូរ | ក្រចេះ |
| | | | កើត | B | 614149 | 1449491 | C | 612271 | 1437067 | | | | |
| | | | ត្បូង | C | 612271 | 1437067 | D | 608071 | 1437066 | | | | |
| | | | លិច | D | 608071 | 1437066 | A | 612210 | 1450908 | | | | |
| ១០ | កន្ទួត | ៧១៦ | ជើង | A | 628468 | 1382182 | B | 629024 | 1378593 | ១ | កន្ទួត | ចិត្របុរី | ក្រចេះ |
| | | | កើត | B | 629024 | 1378593 | C | 627507 | 1378870 | | | | |
| | | | ត្បូង | C | 627507 | 1378870 | D | 627290 | 1381466 | | | | |
| | | | លិច | D | 627290 | 1381466 | A | 628468 | 1382182 | | | | |
| ១១ | ភ្នំហាស | ១៨២៤ | ជើង | A | 642036 | 1393718 | B | 640479 | 1387671 | ១ | ថ្មី | ចិត្របុរី | ក្រចេះ |
| | | | កើត | B | 640121 | 1387671 | C | 637707 | 1387889 | | | | |
| | | | ត្បូង | C | 637707 | 1387889 | D | 639328 | 1393766 | | | | |
| | | | លិច | D | 639328 | 1393766 | A | 642036 | 1393718 | | | | |
| | សរុបផ្ទៃដី | ២១៥៥៨ | | | | | | | | ១១ | ១០ | ៥ | |